# ការដកហូតលិខិតលះបង់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមាន

ខ្ញុំ អៀង សារី សុំដកហូតមកវិញនូវលិខិតលះបង់សិទ្ធិទាំងឡាយរបស់ខ្ញុំ ដែលខ្ញុំបានដាក់ (E229, E237 និង E237/1) អនុលោមទៅតាមវិធានផ្ទៃក្នុង ៨១(៤) និង (៥)។ ពេលខ្ញុំបានចុះលិខិតលះបង់សិទ្ធិទាំងនេះ ខ្ញុំបានជូនដំណឹងយ៉ាងជាក់លាក់ដល់ អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាថា "ខ្ញុំសុំរក្សាសិទ្ធិដើម្បីត្រឡប់មកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីវិញនៅពេលណាមួយ ដែលចាប់ពីពេលនោះមក លិខិតលះបង់សិទ្ធិនេះនឹងលែងមានសុពលភាពទៀតហើយ។" សិទ្ធិរបស់ខ្ញុំក្នុងការមានវត្តមាននេះគឺត្រូវបានធានាចំពោះខ្ញុំដោយ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក, មាត្រា ១២(១) នៃកិច្ចព្រមព្រៀង, វិធាន ៨១(១) នៃវិធានផ្ទៃក្នុង និងមាត្រា ១៤(១) និងមាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

តាមរយៈការដកហូតមកវិញ នូវលិខិតលះបង់ទាំងឡាយដែលមានរៀបរាប់ខាងលើ និងញត្តិស្តីពីការជូនដំណឹងអំពីការដកហូតនូវលិខិតលះបង់សិទ្ធិនានាក្នុងការមានវត្តមាន នៅក្នុងអំឡុងពេលធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន[1] ដែលបានដាក់ក្នុងនាមខ្ញុំដោយសហមេធាវីការពារក្តីរបស់ខ្ញុំគឺ លោក អាង ឧត្តម និង Michael G. Karnavas តាមរយៈនេះ ខ្ញុំជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា <u>ខ្ញុំមានបំណងនឹងចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងបន្ទប់សវនាការ ដោយមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ជាពិសេស នៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី</u> *វៀរលែងតែ* ខ្ញុំ ជ្រើសរើសដោយផ្ទាល់ខ្លួនខ្ញុំ ដើម្បីចូលរួមកិច្ចដំណើរការនីតិវិធីដោយប្រយោលពីបន្ទប់ឃុំឃាំងខាងក្រោមបន្ទប់សវនាការ។

សូមទទួលយកដោយក្តីគោរព

ផ្តិតស្នាមមេដៃ នៅភ្នំពេញ រាជធានីនៃ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ **២០១២**

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Dec-2012, 12:42
CMS/CFO: Sann Rada

**អៀង សារី** / សំណុំរឿង ០០២

[1] សំណៅចម្លងធ្វើជូនជាមុន នៃញត្តិស្តីពីការជូនដំណឹងនេះកំពុងត្រូវបានធ្វើវចែកចាយនៅពេលដែលការដកហូតត្រូវបានដាក់។ ញត្តិស្តីពីការជូនដំណឹងត្រូវដាក់ជាផ្លូវការនៅពេលដែលការបកប្រែត្រូវបានបញ្ចប់។ ញត្តិស្តីពីការជូនដំណឹងនេះ មានរៀបរាប់យ៉ាងលំអិតបន្ថែមទៀត ស្តីពីសិទ្ធិទាំងឡាយរបស់ខ្ញុំទាក់ទងនឹងការចូលរួមដោយផ្ទាល់របស់ខ្ញុំក្នុងបន្ទប់សវនាការ។